# បណ្ដាញកសិករ និងធម្មជាតិ ប្រារព្ធសមាជក្រុមជំនុំថ្នាក់ជាតិ



ក្រោមជំនួយឧបត្ថម្ភពីអង្គការអាគ្រីទែរ៉ា បណ្ដាញកសិករ និងធម្មជាតិ បានរៀបចំសមាជក្រុមជំនុំថ្នាក់ជាតិមួយ នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០៨ ក្រោមការសម្របសម្រួលដោយគ្រូបណ្ដុះបណ្ដាលរបស់បណ្ដាញ ។ សមាជនេះ ធ្វើឡើងក្នុងគោលបំណងរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មាធិការថ្មីដើម្បីរៀបចំរចនាសម្ព័ន្ធថ្មី នៅឆ្នាំ ២០០៩ ដែលជាអនុសាសន៍របស់អង្គការអាគ្រីទែរ៉ា ។ អ្នកចូលរួមសរុបមានចំនួចំនួន ៤៨ នាក់ ( ស្ត្រី ១៤ នាក់) មកពី ៤៤ ភូមិ ៤០ ឃុំ ២៣ ស្រុក និង ១០ ខេត្ត ដែលជាគណៈកម្មាធិការទាំងប្រាំរូបក្នុងខេត្តនីមួយៗ និងតំណាងជំនាញចូលរួម ហើយក៏មានតំណាងរបស់ AFD ចំនួន ៣ នាក់ចូលរួមដើម្បីធ្វើការសង្កេតការណ៍ផងដែរ ។ នៅក្នុងកំឡុងពេលសមាជផងដែរ លោក **ហេង សុជាតិ** ដែលជាជំនួយការមូលដ្ឋានបណ្ដាញបានធ្វើបទបង្ហាញអំពីរបាយការណ៍សកម្មភាពរបស់បណ្ដាញនៅក្នុងឆ្នាំ ២០០៨ និងរបាយការណ៍ថវិការនៅឆ្នាំ ២០០៨ និងទឹកប្រាក់ទ្រទ្រង់ដែលប្រមូលបានពីតាមសមាគមដើម្បីតម្កល់ទុកសំរាប់ចាយនៅថ្នាក់ខេត្ត បង្ហាញដោយ កញ្ញា **គង់ សុខឈាន់** ជាលេខាធិការបណ្ដាញ។

ជាលទ្ធផល ឆ្លងតាមការបោះឆ្នោតដ៏ត្រឹមត្រូវ និងយុត្តិធម៌ លោក **អួន សុផល** ដែលជាតំណាងកសិករមកពីខេត្តកំពតបានជាប់ឆ្នោតជាប្រធានបណ្ដាញកសិករ និងធម្មជាតិ ហើយលោក **ជា សុភ័ក្តិ** ជាប់ឆ្នោតជាអនុប្រធាន និងអ្នកស្រី **ឃួន សី** ជាហិរញ្ញិក។